ក្រុមហ៊ុន ស៊ីនយ៉ុងសឹង ហ្គាម៉ិន(ខេមបូឌា)ឯ.ក
鑫永盛制衣(柬埔寨)有限公司
XINYONGSHENG GARMENT ( CAMBODIA ) CO., LTD
អាសយដ្ឋានសហគ្រាសៈ ក្បាលដីលេខ៨០៤ ផ្លូវ ចោមចៅ ភូមិ ដំណាក់ធំ៥ សង្កាត់ ស្ទឹងមានជ័យទី៣ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ
Address: Chom Chao street, Phuket Damnak Thum 5, Sangkat Stueng Mean Chet 3, Khan Mean Chet, Phnom Penh
Phone: (+855)12 938066

# កិច្ចព្រមព្រៀងស្តីអំពីព្យួរកិច្ចសន្យាការងារ
# ចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ ថ្ងៃទី០៥ ខែ មីនា ឆ្នាំ២០២៣

កិច្ចព្រមព្រៀងស្តីអំពីព្យួរការងារ បានធ្វើឡើងនៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២៣ រវាងក្រុមហ៊ុន ស៊ីងយ៉ុងសឹង ហ្គាម៉ិន (ខេមបូឌា) ឯ.ក ហៅថាភាគី "ក" តំណាងអោយនិយោជក ជាមួយតំណាងកម្មករ ប្រធានក្រុម ប្រធានផ្នែក ប្រចាំរោងចក្រហៅថាភាគី "ខ"

ភាគីទាំងពីរបានយល់ព្រមលើកិច្ចព្រមព្រៀងមានដូចខាងក្រោម៖

១.ភាគី"ក"ត្រូវព្យួរកិច្ចសន្យាការងារកម្មករមួយចំនួន ចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៣ ។

២.ភាគី"ក"និងផ្តល់ចំនួននិងឈ្មោះកម្មករដែលធ្វើការនៅផ្នែកនីមួយៗដែលត្រូវព្យួរការងារ។

៣.ភាគី "ក" ព្យួរកិច្ចសន្យាការងារចំពោះកម្មករដែរធ្វើការនៅផ្នែកតុកាត់ ផ្នែកខ្លះនៃក្រុមដេរ ផ្នែកQC និង ផ្នែកវេចខ្ចប់ ផ្នែកអ៊ុត ចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៣ ។

៤.កម្មករដែលព្យួរការងារត្រូវទទួលបានប្រាក់ ១៥ដុល្លារ បូក ៧ដុល្លារ សំរាប់ការស្នាក់នៅ និងធ្វើដំណើរដែលច្បាប់បានកំណត់ សរុប ២២ដុល្លារ កម្មករត្រូវមកទទួលប្រាក់នេះ មុនពេលកម្មករ កម្មការនីព្យួរកិច្ចសន្យាការងារ គឺត្រូវនឹងថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២៣ បញ្ជាក់៖ បើសិនជាកម្មករដែល បានព្យួរកិច្ចសន្យាការងារ បានបំពេញការងារ បានមួយខែពេញវិញបន្ទាប់ ព្យួរកិច្ចសន្យា ការងារ ភាគី"ក" និងបន្ថែម៥០ដុល្លារ ជូនកម្មករដែលបានព្យួរកិច្ចសន្យាការងារ។

៥.កម្មករមិនទទួលបានប្រាក់ឈ្នួលប្រចាំថ្ងៃ ប្រាក់រង្វាន់ ប្រាក់ឧបត្ថម ប្រាក់មុខងារ និងផលប្រយោជន៍ផ្សេងទៀតដែលមិនបានតម្រូវ ដោយច្បាប់នៅក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ។

៦.ភាគី"ក"ព្យួរកិច្ចការងាររបស់កម្មករដោយរោងចក្រអត់មានការបញ្ជាទិញពីអតិថិជន។

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅចំពោះមុខតំណាងកម្មករ និងប្រធានក្រុម ប្រធានផ្នែក បានឯកភាពទាំងសងខាងនិងមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើង។

ភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០២៣

| ហត្ថលេខា និងត្រា | ហត្ថលេខា និងស្នាមមេដៃ |
| --- | --- |
| ភាគី"ក" | ភាគី"ខ" |

XINYONGSHENG GARMENT (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

REN XIAO FEI

Han Bunthan